[07]

# Wisdom and Compassion

***Q. What do the terms wisdom and compassion mean in Buddhism?***

A. Some religions believe that compassion or love (the two are very similar) is the most important spiritual quality but they fail to develop any wisdom. The result is that you end up being a good-hearted fool, a very kind person but with little or no understanding. Other systems of thought, like science, believe that wisdom can best be developed when all emotions, including compassion, are kept out of the way. The outcome of this is that science has tended to become preoccupied with results and has forgotten that science is to serve man, not to control and dominate him. How, otherwise could scientists have lent their skills to develop the nuclear bomb, germ warfare, and the like. Religion has always seen reason and wisdom as the enemy of emotions like love and faith. Science has always seen emotions like love and faith as being enemies of reason and objectivity. And of course, as science progresses, religion declines. Buddhism, on the other hand, teaches that to be a truly balanced and complete individual, you must develop both wisdom and compassion. And because it is not

ភាគ ៧

# បញ្ញា និង មេត្តាធម៌

***ម្ម. តើពាក្យថាបញ្ញា និងមេត្តា មានអត្ថន័យដូចម្ដេចក្នុងព្រះពុទ្ធសាសនា?***

**ទិ.** សាសនាខ្លះជឿថាមេត្តាធម៌ ឬសេចក្ដីស្រលាញ់ (ពាក្យទាំងពីរគឺមានន័យស្រដៀងគ្នាណាស់) ជាគុណភាពខាងផ្លូវចិត្តដ៏សំខាន់បំផុតមួយ តែពួកគេមិនបានយកចិត្តទុកដាក់អភិវឌ្ឍន៍បញ្ញាឡើយ។ ជាលទ្ធផលគឺអ្នកចប់ជាចុងក្រោយដោយក្លាយជាមនុស្សចិត្តល្អល្ងីល្ងើ ជាមនុស្សមានសន្ដានចិត្តល្អណាស់ តែមានសេចក្ដីយល់ដឹងតិចតួចឬគ្មានសោះឡើយក៏មាន។ ដូចគ្នានឹងវិទ្យាសាស្ដ៍ដែរ ប្រព័ន្ធនៃទ្រឹស្ដីមួយទៀតដែលគេជឿថាបញ្ញាអាចអភិវឌ្ឍន៍ដល់កំពូលបានពេលដែលមនោសញ្ចេតនាទាំងអស់ រួមទាំងមេត្តាធម៌ ត្រូវបានទុកដោយឡែកពីគេ។ ការអធិប្បាយរឿងនេះគឺថា ស្យង់មានទិសដៅក្លាយជាអ្នកគ្រប់គ្រងមុនគេនូវលទ្ធផល ហើយបំភ្លេចរឿងនោះចោល ស្យង់គឺជាអ្នកបំរើមនុស្សមិនមែនជាអ្នកគ្រប់គ្រងឬជិះជាន់មនុស្សទេ។ យ៉ាងណាក៏ដោយអ្នកវិទ្យាសាស្ដ៍ឱ្យគេខ្ចីនូវចំណេះដឹងជំនាញរបស់ខ្លួនទៅឱ្យអ្នកដទៃអភិវឌ្ឍន៍គ្រាប់បែកបរមាណូមេរោគសង្គ្រាម និងផ្សេងៗទៀត។ ជានិច្ចជាកាលសាសនាឃើញហេតុផលនិងបញ្ញាជាសត្រូវនៃមនោសញ្ចេតនាទាំងឡាយដូចជាសេចក្ដីស្រលាញ់និងជំនឿ។ ស្យង់ជានិច្ចជាកាលមើលឃើញមនោសញ្ចេតនាដូចជាការស្រឡាញ់និងជំនឿថាជាសត្រូវនៃហេតុផលនិងគោលការណ៍។ ហើយតាមពិតទៅ ពេលដែលស្យង់មានការរីកចំរើន សាសនាក៏ដួលរលំ។ ម្យ៉ាងវិញទៀតព្រះពុទ្ធសាសនា បង្រៀនឱ្យមានការធ្វើឱ្យបច្ចេកបុគ្គលម្នាក់ៗបានសម្រេចជោគជ័យនិងមានតុល្យភាពយ៉ាងពិតប្រាកដ ដែលមនុស្សត្រូវតែអភិវឌ្ឍន៍ទាំងបញ្ញានិងមេត្តាធម៌។ ហើយព្រោះតែវាមិនមែន

dogmatic but based on experience, Buddhism has nothing to fear from science.

***Q. So what, according to Buddhism, is wisdom?***

A. The highest wisdom is seeing that in reality all phenomena are incomplete, impermanent, and not self. This understanding is totally freeing and leads to the great security and happiness which is called Nirvana. However, the Buddha doesn't speak too much about this level of wisdom. It is not wisdom if we simply believe what we are told. True wisdom is to directly see and understand for ourselves. At this level then, wisdom is to keep an open mind rather than being closed-minded, listening to other points of view rather than being bigoted; to carefully examine facts that contradict our beliefs, rather than burying our heads in the sand; to be objective rather than prejudiced and partisan; to take time about forming our opinions and beliefs rather than just accepting the first or most emotional thing that is offered to us; and to always be ready to change our beliefs when facts that contradict them are presented to us. A person who does this is certainly wise and is certain to eventually arrive at true understanding. The path of just believing what you are told is easy. The Buddhist path requires courage, patience, flexibility and intelligence.

***Q. What is the point of Buddhism if only a few can practice it?***

លទ្ធិប្រកាន់ជ្រុល តែអាស្រ័យទៅលើការពិសោធន៍ ធ្វើឱ្យព្រះពុទ្ធសាសនាគ្មានអ្វីគួរឱ្យភ័យខ្លាចចំពោះវិទ្យាសាស្ត្រទាល់តែសោះ ។

**ប្ុ.** ***ដូច្នេះ អាស្រ័យតាមព្រះពុទ្ធសាសនា តើអ្វីគឺជាបញ្ញា?***

**ទិ.** បញ្ញាដ៏ខ្ពង់ខ្ពស់បំផុតគឺមើលឃើញវត្ថុគ្រប់យ៉ាងតាមសេចក្តីពិតដែលកើតឡើងដូចជាឃើញថាជាទុក្ខំ អនិច្ចំ និងអនត្តា។ ការយល់ដូចនេះគឺជាសេរីភាពទាំងស្រុង ហើយនាំទៅរកសុវត្ថិភាពនិងសុភមង្គលដ៏អស្ចារ្យមួយដែលគេហៅថាព្រះនិព្វាន។ ទោះជាយ៉ាងណាក៏ដោយ ព្រះពុទ្ធបរមគ្រូមិនត្រាស់ច្រើនទេអំពីបញ្ញាកំរិតនេះ។ វាមិនមែនជាបញ្ញាបើយើងជឿយ៉ាងងាយនូវអ្វីដែលគេប្រាប់យើង។ បញ្ញាពិតប្រាកដគឺឃើញនិងយល់ដោយត្រង់ដោយខ្លួនឯង។ បញ្ញាកំរិតនេះ ពេលនោះជាបញ្ញាដែលធ្វើចិត្តឱ្យទូលាយជាងចិត្តចង្អៀតចង្អល់ មានការចេះស្តាប់ទស្សនៈរបស់អ្នកដទៃជាជាងការស្រើងរង្វែងនឹងខ្លួនឯង ពិនិត្យពិចារណានូវហេតុការណ៍យ៉ាងយកចិត្តទុកដាក់នូវអ្វីដែលផ្ទុយពីជំនឿរបស់ខ្លួនឯង ជាជាងការបង្កប់ក្បាលខ្លួនឯងទៅក្នុងដីខ្សាច់ ធ្វើខ្លួនឯងជាមនុស្សចូលសង្គមគេបានជាជាងការប្រកាន់ខ្លួននិងការប្រកាន់បក្សពួក ប្រើពេលវេលាក្នុងការបញ្ចេញមតិរបស់យើងនិងជំនឿជាជាងគ្រាន់តែទទួលយល់ព្រមនូវរឿងដែលរំភើបខ្លាំងឬរឿងដំបូងដែលគេប្រាប់យើង ហើយជានិច្ចជាកាល គឺត្រៀមខ្លួនជាស្រេចដើម្បីកែប្រែជំនឿរបស់យើង នៅពេលដែលហេតុការណ៍គេផ្តល់ឱ្យយើងផ្ទុយស្រឡះពីយើង។ មនុស្សដែលធ្វើដូចនេះគឺជាមនុស្សឆ្លាតដ៏ពិតប្រាកដ ហើយនៅទីបំផុតពិតជាទទួលបាននូវការយល់ដឹងដែលពិតប្រាកដ។ មគ្គាដែលគ្រាន់តែការជឿនូវអ្វីដែលគេប្រាប់អ្នកគឺងាយណាស់។ វិធីព្រះពុទ្ធសាសនាទាមទារឱ្យយើងក្លាហាន អត់ធន់ រស់រវើក និងឆ្លាតវាងវៃ ។

**ប្ុ.** ***តើគោលនៃព្រះពុទ្ធសាសនាគឺអ្វីបើមានតែពីរបីនាក់ប៉ុណ្ណោះអាចបដិបត្តិបាន?***

A. It is true that not everyone is ready for Buddhism yet. But to say therefore that we should teach a religion that is false but easily understandable so everyone can practise it is ridiculous. Buddhism aims at the truth and if not everyone has the capacity to understand it yet, they perhaps will be ready for it in their next life. However, there are many who, with just the right words or encouragement, are able to increases their understanding. And it is for this reason that Buddhists gently and quietly strive to share the insights of Buddhism with others. The Buddha taught us out of compassion and we teach others out of compassion.

**Q. *What, according to Buddhism, is compassion?***

A. Just as wisdom covers the intellectual or comprehending side of our nature. Like wisdom, compassion is uniquely human quality. Compassion is made up of two words. 'co' meaning together and 'passion' meaning a strong feeling. And this is what compassion is. When we see someone is in distress and we feel their pain as if it were our own, and strive to eliminate or lessen their pain, then this is compassion. So all the best in human beings, all the Buddha-like qualities like sharing, readiness to give comfort, sympathy, concern and caring - all are manifestations of compassion.

**ទិ.** វាជាសេចក្ដីពិតដែលអ្នករាល់គ្នាមិនទាន់ត្រៀមខ្លួនជាស្រេចចូលកាន់ព្រះពុទ្ធសាសនានៅឡើយ។ តែទោះបីនិយាយដូច្នោះក៏ដោយ យើងក៏អាចបង្រៀនសាសនាបែបក្លែងក្លាយ តែធ្វើឱ្យអ្នកទាំងអស់គ្នាយល់បានយ៉ាងងាយ អាចបដិបត្តិបានដែលមិនគួរឱ្យជឿ។ ព្រះពុទ្ធសាសនាតាំងគោលដៅទៅរកសច្ចភាព បើអ្នកទាំងអស់គ្នាមិនមានសមត្ថភាពយល់ដឹងវាទេ ពួកគេគង់នឹងត្រៀមខ្លួនជាស្រេចដើម្បីវានៅជាតិខាងមុខរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយមានមនុស្សជាច្រើនដែលគ្រាន់តែមានពាក្យត្រឹមត្រូវឬការលើកទឹកចិត្ត អាចនឹងលើកកំពស់សេចក្ដីយល់ដឹងរបស់ពួកគេ។ ហើយសំរាប់ហេតុផលនេះដែលពុទ្ធសាសនិកជនពុះពារយ៉ាងស្ងាត់ៗនិងទន់ភ្លន់ដើម្បីចូលរួមធ្វើឱ្យយល់ច្បាស់នូវព្រះពុទ្ធសាសនាជាមួយអ្នកដទៃ។ ព្រះពុទ្ធបរមគ្រូបានបង្រៀនយើងឱ្យផ្សាយមេត្តាធម៌ ហើយយើងបង្រៀនអ្នកដទៃឱ្យផ្សាយមេត្តាធម៌ផងដែរ ។

**សុ.** ***អាស្រ័យតាមព្រះពុទ្ធសាសនា តើអ្វីគឺជាមេត្តាធម៌?***

**ទិ.** បញ្ញាគ្រាន់តែគ្របដណ្ដប់ទៅលើផ្នែកយល់ដឹងឬបញ្ញានៃធម្មជាតិរបស់យើង។ ដូចគ្នានឹងបញ្ញា មេត្តាធម៌គឺជាគុណភាពពិសេសមួយរបស់មនុស្ស។ មេត្តាធម៌បង្កើតឡើងដោយពាក្យពីរម៉ាត់។ *កូ* មានន័យថារួមគ្នា និង *ផាស់សិន* មានន័យថាអារម្មណ៍ដ៏ជ្រាលជ្រៅ។ ហើយនេះគឺជាអត្ថន័យរបស់ពាក្យមេត្តាធម៌។ ពេលយើងឃើញនរណាម្នាក់ទុក្ខព្រួយហើយយើងមានអារម្មណ៍ថាសេចក្ដីចុកចាប់របស់ពួកគេ ហាក់ដូចជារបស់យើងផ្ទាល់ ហើយព្យាយាមពុះពារលុបបំបាត់ឬធ្វើឱ្យថយចុះនូវសេចក្ដីចុកចាប់របស់ពួកគេ ហើយនេះគឺជាមេត្តាធម៌។ ដូច្នេះភាពល្អបំផុតសំរាប់មនុស្សលោកយើង ភាពជាព្រះពោធិសត្វទាំងឡាយចូលចិត្តចែករំលែក ត្រៀមជាស្រេចនឹងឱ្យគេបានសុខ ករុណាធម៌ យកចិត្តទុកដាក់និងគាំពារ-ទាំងអស់នេះគឺបញ្ជាក់នូវមេត្តាធម៌។

You will notice also that in the compassionate person, care and love towards others has its origins in care and love for oneself. We can really understand others when we really understand ourselves. We will know what's best for others when we know what's best for ourselves. We can feel for others when we feel for ourselves. So in Buddhism, ones own spiritual development blossoms quite naturally into concern for the welfare of others. The Buddha's life illustrates this very well. He spent six years struggling for his own welfare, after which, he was able to be of benefit to the whole of mankind.

អ្នកនឹងសង្កេតផងដែរនូវអ្វីមានក្នុងមនុស្សប្រកបដោយមេត្តាធម៌គាំពារនិងស្រឡាញ់ចំពោះអ្នកដទៃ មានប្រភពរបស់វាមកពីការគាំពារនិងស្រឡាញ់ខ្លួនឯង។ យើងអាចយល់អ្នកដទៃយ៉ាងច្បាស់ពេលដែលយើងយល់ខ្លួនយើងបានច្បាស់។ យើងនឹងដឹងអ្វីដែលជាចំណុចខ្លាំងរបស់អ្នកដទៃពេលយើងដឹងនូវចំណុចខ្លាំងរបស់ខ្លួនយើង។ ដូច្នេះ ក្នុងព្រះពុទ្ធសាសនា មនុស្សម្នាក់ជាកម្មសិទ្ធក្នុងការអភិវឌ្ឍន៍ផ្លូវសតិស្មារតី ឱ្យរីកស្គុះស្គាយតាមធម្មជាតិពិតប្រាកដចូលទៅក្នុងសុខមាលភាពរបស់អ្នកដទៃ។ ជីវិតរបស់ព្រះពុទ្ធបរមគ្រូលាតត្រដាងបង្ហាញនូវរឿងនេះបានយ៉ាងច្បាស់។ ព្រះអង្គចំណាយពេល៦ឆ្នាំប្រយុទ្ធប្រឆាំងនូវសុខមាលភាពខ្លួនឯង បន្ទាប់ពីពេលដែលព្រះអង្គអាចក្លាយជាអ្នកធ្វើប្រយោជន៍ដល់មនុស្សលោកទាំងមូល។

**Q.** ***Isn't it selfish to say that we are best able to help others after we have helped ourselves.***

A. We usually see altruism, concern for others before oneself, as being the opposite of selfishness, concern for oneself before others,. Buddhism does no see it as either one or the other but rather as a blending of the two. Genuine self-concern will gradually mature into concern for others as one sees that others are really the same as oneself. This is genuine compassion. Compassion is the most beautiful jewel in the crown of the Buddha's teaching.

**ឬ.** *តើវាមិនមែនជាបុគ្គលនិយមឬទេ ដែលនិយាយថាយើងគឺចំណុចខ្លាំងបំផុតដែលអាចជួយអ្នកដទៃបន្ទាប់ពីយើងបានជួយខ្លួនយើង ។*

**ទ.** ជាធម្មតាយើងមើលឃើញបរត្ថភាព ឱ្យការយកចិត្តទុកដាក់ទៅលើអ្នកដទៃមុនខ្លួនយើង ជាភាពផ្ទុយគ្នាស្រឡះពីអត្តទត្ថបុគ្គលដែលមើលឃើញផលប្រយោជន៍ផ្ទាល់ខ្លួនមុនអ្នកដទៃ។ ព្រះពុទ្ធសាសនាមិនមើលឃើញមួយណាសំខាន់ជាងមួយណាទេ តែមើលឃើញជាទំរង់ច្របាច់ចូលគ្នាទាំងពីរ។ ការយកចិត្តទុកដាក់តែលើខ្លួនឯងពិតប្រាកដ នឹងក្លាយខ្លួនជាបន្តបន្ទាប់ចំពោះការយកចិត្តទុកដាក់ដល់អ្នកដទៃ ដូចដែលមនុស្សម្នាក់នោះឃើញថាប្រយោជន៍អ្នកដទៃពិតជាដូចគ្នានឹងប្រយោជន៍ផ្ទាល់ខ្លួន។ នេះគឺជាមេត្តាធម៌ដ៏ពិតប្រាកដ។ មេត្តាធម៌គឺជាគ្រាប់ពេជ្រមានរូបឆោមល្អស្រស់បំផុតក្នុងមកុដរបស់ពាក្យប្រៀនប្រដៅព្រះពុទ្ធបរមគ្រូនៃយើង ។